MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង
# នៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ
## សំរាប់អាងទន្លេមេគង្គភាគខាងក្រោម



# អារម្ភកថា

**តាងនាមឱ្យក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ** (MRC) ខ្ញុំមានក្តីសោមនស្សរីករាយជាពន្លឹកក្នុងការបង្ហាញជូននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គភាគខាងក្រោម(LMB) ដោយមានការចូលរួមសហការ និងការរៀបចំពីបណ្តាប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ (កម្ពុជា ឡាវ ថៃ និងវៀតណាម) ផ្អែកទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ។

ដោយមានការព្រមព្រៀងពីក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ការចូលរួមរៀបចំយុទ្ធសាស្ត្រនេះគឺ ជាសមិទ្ធិផលសំខាន់មួយឆ្ពោះទៅការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គដោយចីរភាព។ យុទ្ធសាស្ត្រនេះ ស្របតាមសេចក្តីថ្លែងការណ៍នៃជំនួបកំពូលរបស់គណៈកម្មការទន្លេមេគង្គលើទី១ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ នៅហួហ៊ីន ប្រទេសថៃ ដោយទទួលស្គាល់ថាភាពជឿនលឿននៃការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ ប៉ុន្តែទន្ទឹមនេះក៏មានការទទួលស្គាល់ដែរថាអាចមានផលប៉ះពាល់អវិជ្ជមានដែលតម្រូវឱ្យយកចិត្តទុកដាក់បរិស្ថានអាងបានពេញលេញ ។

ចាប់តាំងពីចុះហត្ថលេខាដំបូងលើកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ បានចូលរួមចែករំលែកការយល់ដឹងអំពីកាលានុវត្តភាព និងហានិភ័យនៃផែនការជាតិសម្រាប់ការអភិវឌ្ឍ និងបានឯកភាពទៅលើអាទិភាពយុទ្ធសាស្ត្រមួយចំនួន ដើម្បីធ្វើឱ្យប្រសើរដល់កាលានុវត្តភាពអភិវឌ្ឍន៍ និងកាត់បន្ថយភាពមិនច្បាស់លាស់ និងហានិភ័យដែលពាក់ព័ន្ធឱ្យដល់កម្រិតអប្បបរមា។ កត្តានេះជួយដល់ការអនុវត្តនីតិវិធីដែលបានឯកភាពក្រោមកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ឱ្យបានសម្រេចទាន់ពេលវេលា ។

ប្រទេសដែលជាសមាជិកបានទទួលស្គាល់នូវតម្រូវការ ដើម្បីបន្តអភិវឌ្ឍន៍កាលានុវត្តភាព ទាក់ទងនឹងទឹក (កាត់បន្ថយហានិភ័យពីទឹកជំនន់និង គ្រោះរាំងស្ងួត ជលផល និងនាវាចរណ៍) ក៏ដូចជាកាលានុវត្តភាពក្រៅ ពីវិស័យទឹកដែលផ្តល់លទ្ធភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងដើម្បីឆ្ពោះទៅការអភិវឌ្ឍអាងប្រកបដោយចីរភាព ។

ប្រទេសដែលជាសមាជិកទទួលស្គាល់នូវអាទិភាពបន្ទាន់ ដើម្បីអភិវឌ្ឍន៍ និងឯកភាពលើកម្មវត្ថុ សង្គម និងបរិស្ថានអាង និងសូមយកមូលដ្ឋានយ៉ាងទូលំទូលាយសម្រាប់ធ្វើការពិចារណា និងដើម្បីអនុវត្តកិច្ចអភិវឌ្ឍន៍ និងណែនាំការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះនាពេលអនាគត។

យើងយល់ដឹងពីសារៈសំខាន់ចាំបាច់នៃការគ្រប់គ្រងអាងដែលត្រូវពង្រឹង និងជាពិសេសលើកម្មវិធី ផ្អែកកសាងសមត្ថភាពធនធានមនុស្សក្នុងការអភិវឌ្ឍអាងប្រកបដោយចីរភាព ការចាត់ចែងរៀបចំ សមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស។ ការអនុវត្តយុទ្ធសាស្ត្រនេះដោយជោគជ័យ ត្រូវទាមទារឱ្យមានការប្តេជ្ញាពីបណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គទាំងពីរអ្នកអភិវឌ្ឍគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងកិច្ចប្រឹងប្រែងឱ្យបានប្រសើរបំផុតលើសកម្មភាពគ្រប់គ្រងទឹក និងធនធានទាក់ទងនានា ជាមួយក្របខ័ណ្ឌដែលបានលំអិតនៅក្នុងយុទ្ធសាស្ត្រនេះ ។

តាងនាមឱ្យក្រុមប្រឹក្សាគណៈកម្មាទន្លេមេគង្គ ខ្ញុំស្នើសូមលើកទឹកចិត្តឱ្យមានការចូលរួមសហការ គាំទ្រជាមួយការងាររបស់យើងនៅក្នុងយុទ្ធសាស្ត្រនេះ ។



Pham Khoi Nguyen
ប្រធានក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ
ឆ្នាំ២០១០-២០១១

# សេចក្ដីសង្ខេប

## ការទទួលយកយុទ្ធសាស្ត្រ ចំណុចគោលសំខាន់

ការរៀបចំនិងការទទួលយកនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះដោយបណ្ដាលប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោម (LMB) គឺជាចំណុចគោលសំខាន់មួយនៅក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌគណៈកម្មាការទន្លេមេគង្គ ចំពេលដែលអាង និងទន្លេមេគង្គ ដែលជាទន្លេធំក្នុងចំណោមទន្លេធំជាងគេនានាក្នុងពិភពលោកកំពុង ត្រូវបានគេមើលឃើញថាមានការប្រែប្រួលយ៉ាងខ្លាំង។ ការប្រែប្រួលទាំងនេះរួមមានទាំងការប្រែប្រួលផ្នែកប្រជាសាស្ត្រ សេដ្ឋកិច្ច ធាតុអាកាស និងវារីសាស្ត្រ ដែលទទួលរងឥទ្ធិពលពីចលករថ្នាក់ជាតិ កម្រិតតំបន់ និងកម្រិតពិភពលោក។

ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចតម្រូវឱ្យមានការអភិវឌ្ឍធនធានទឹកសម្រាប់គោលបំណងច្រើនយ៉ាង រួមទាំងផលិតផលថាមពល ផលិតកម្មកសិកម្ម និងជលផល និងការធ្វើពាណិជ្ជកម្មតាមទន្លេ។ ប្រការនេះ ក៏ទាមទារផងដែរនូវការគ្រប់គ្រងទន្លេ និងជីវភាពប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេដើម្បីធានានិរន្តរភាពសម្រាប់រយៈពេលវែង។ ការធានានិរន្តរភាពសម្រាប់រយៈពេលវែងដែលកាន់តែលំបាកខណៈ ដែលទន្លេមេគង្គកំពុងប្រឈមនឹងការប្រែប្រួលអាកាសធាតុ។

ការអភិវឌ្ឍនៅតំបន់ឡានឆាងនៅក្នុងអាងទន្លេមេគង្គភាគខាងលើក្នុងប្រទេសចិន និងនៅតំបន់អាងទន្លេមេគង្គភាគខាងក្រោមកំពុងធ្វើឱ្យមានការផ្លាស់ប្ដូររបបលំហូរនៅទន្លេមេគង្គ ។ បច្ចុប្បន្នវិស័យឯកជនកំពុងស្វែងរក កាលានុវត្តភាពវិនិយោគយ៉ាងសកម្ម ដើម្បីបំពេញកំណើនតម្រូវការ ផលិតផលនិងសេវាកម្ម ដែលទន្លេនេះអាចផ្ដល់បាន ប្រសិនបើមានប្រព័ន្ធនិយ័តកម្មប្រកបដោយប្រសិទ្ធភាពត្រឹមត្រូវមួយមាននៅនឹងន្លែង។

យុទ្ធសាស្ត្រនេះ គឺជាការឆ្លើយតបមួយដែលមានអត្ថប្រយោជន៍ និងអាចធ្វើទៅបានដោយប្រទេសនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនេះ។ ការឆ្លើយតបអាចមានដូចជា តាមរយៈការដកចេញនូវរបាំងដែលរារាំងដល់កាលានុវត្តភាពនៃកិច្ចអភិវឌ្ឍន៍ទន្លេមេគង្គដោយចីរភាព។

ចំណុចសំខាន់នៃយុទ្ធសាស្ត្រនេះ គឺចំណាត់ការលើសកិច្ចសហប្រតិបត្តិការ ជាពិសេសលើការទទួលបានចំណេះដឹង ឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រង និងការអភិវឌ្ឍទឹក និងចំណាត់ការលើសពីការធ្វើផែនការតាមវិស័យនៅកំរិតថ្នាក់ជាតិឆ្ពោះទៅការធ្វើផែនការអាងឱ្យបានទូលំទូលាយ ។

## យុទ្ធសាស្ត្រ: កសាងមូលដ្ឋានគ្រឹះរឹងមាំ

មូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រនេះ មានចែងក្នុងកិច្ចព្រមព្រៀង ដើម្បីសហប្រតិបត្តិការដោយចីរភាពនៃអាងទន្លេមេគង្គឆ្នាំ១៩៩៥។យុទ្ធសាស្ត្រនេះជាការឆ្លើយតបចំបងរបស់គណៈកម្មការទន្លេមេគង្គ ចំពោះមាត្រា២ ដែលអំពាវនាវអោយមាន ការបង្កើតផែនការអភិវឌ្ឍអាង ដើម្បីកំណត់ធ្វើចំណាត់ថ្នាក់ និងធ្វើអាទិភាពគម្រោង និងកម្មវិធីនានាសំដៅស្វែងរកការជួយគាំទ្រការអនុវត្តនៅកម្រិតទូទាំងអាងទន្លេមេគង្គ។ មូលដ្ឋាននេះ បង្ហាញផ្លូវគោលសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ទឹក នៅអាងទន្លេមេគង្គភាគខាងក្រោមប្រកបដោយចីរភាពនិង ដោយមានកិច្ចសហប្រតិបត្តិការដោយទទួលស្គាល់ថាទិន្នន័យ និងចំណេះដឹងនៅមានកំណត់ និងទទួលស្គាល់អំពីភាព ចាំបាច់បន្ទាន់សម្រាប់សកម្មភាព ដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍ និងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង។

ដូច្នេះ យុទ្ធសាស្ត្រនេះកំណត់ដំណើរការធ្វើផែនការអភិវឌ្ឍអាងយ៉ាងសកម្មដែលនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ សំដៅធានាថាការឆ្លើយតប និងចំណេះដឹងថ្មីៗ។ ការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះលើកទីមួយ ត្រូវបានគេរំពឹងថានឹងធ្វើក្នុងឆ្នាំ២០១៥ ។

## យុទ្ធសាស្ត្រស្តីពីកាលានុវត្តភាព និងហានិភ័យដែលពាក់ព័ន្ធ

កាលានុវត្តភាពអភិវឌ្ឍន៍ទឹកនៅអាងទន្លេមេគង្គភាគខាងក្រោម មានច្រើនដែលអាចផ្តល់ផលប្រយោជន៍សំខាន់នៅថ្នាក់ជាតិ និងតាមរយៈកិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់។ កាលានុវត្តភាពនេះ ក៏មានហានិភ័យ និងផលវិបាកធំផង ដែរដែលចាំបាច់ត្រូវមានការគ្រប់គ្រងនិងកាត់បន្ថយទាំងនៅថ្នាក់ជាតិ និងនៅកម្រិតពាក់ព័ន្ធទាំងអស់តាមរយៈ កិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិតអន្តរព្រំដែនទាំងអស់។ យុទ្ធសាស្ត្រនេះកំណត់អត្តសញ្ញាណនៃកាលានុវត្តភាព និងហានិភ័យដែលពាក់ព័ន្ធដូចតទៅ :

- សក្តានុពលធំធេញជាច្រើនសម្រាប់ការអភិវឌ្ឍវារីអគ្គីសនីនៅតាមដៃទន្លេ ជាពិសេសនៅប្រទេសឡាវ និងកម្ពុជា ដែលទាមទារឱ្យមានស្តង់ដាបរិស្ថាន និងសង្គមរួមមួយដើម្បីធានានិរន្តរភាព។

- សក្តានុពលធំៗសម្រាប់ពង្រីក និងកំណត់អត្តសញ្ញាណផលិតកម្មកសិកម្មដោយប្រព័ន្ធស្រោចស្រពសំដៅបង្កើនសន្តិសុខស្បៀងក្នុងនោះរួមទាំងការប្រើប្រាស់ទឹកពីទន្លេមេគង្គភាគខាងក្រោម និងដើម្បីទប់ទល់ ការហូរចូលទឹក ប្រៃមកកាន់តំបន់ដីសណ្តរយោងទៅតាមការសម្របសម្រួលនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដទៃទៀតនៃទន្លេមេគង្គសំដៅ ធ្វើប្រតិបត្តិការរក្សាទំនប់វារីអគ្គីសនីដែលកំពុងដំណើរការ និងក្នុងគម្រោងក្នុងន័យធានាបានភាពល្អប្រសើរថែមទៀតសំរាប់ការត្រួតពិនិត្យ និងរក្សាបាននូវលំហូរទឹកនៅរដូវប្រាំង។

- សក្តានុពលសម្រាប់ការអភិវឌ្ឍវារីអគ្គីសនីនៅតាមទន្លេមេ ប្រសិនបើភាពមិនច្បាស់លាស់ និងហានិភ័យត្រូវបានដោះស្រាយទាំងស្រុងនិងការ វាយតម្លៃកំរិតឆ្លងព្រំដែនតំបន់ព្រមទាំងដំណើរ

ការឯកភាពគ្នាត្រូវបានអនុវត្ត។ ទោះបីជាផលប្រយោជន៍ ដែលអាចមានខ្ពស់ពិតមែន ការចំណាយក៏មានខ្ពស់ដែរ រួមទាំង ផលប៉ះពាល់នៅតាមឆ្លងព្រំដែន និង

- សក្តានុពលសម្រាប់ការអភិវឌ្ឍទាក់ទងនឹងទឹកជាអាទិភាព (ជលផល នាវាចរណ៍ ការគ្រប់គ្រងស្បៀងនិង គ្រោះរាំងស្ងួត ទេសចរណ៍និងបរិស្ថាន និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី) ក៏ដូចជាទៅលើបញ្ហាផ្សេងៗទៀត ក្រៅពីវិស័យទឹកផងដែរ ជម្រើសនៃការផលិតថាមពលផ្សេងៗ ។

## យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍអាង

យុទ្ធសាស្ត្រនេះ ឱ្យនិយមន័យពីដំណើរការមួយដើម្បីឈានពីកាលានុវត្តភាពទៅរកការអនុវត្ត និងការអភិវឌ្ឍដោយចីរភាព ដែលក្នុងនោះរួមមានទាំងកំណត់និយមន័យសំរាប់អាទិភាពជាយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍអាងដូចតទៅ ៖

- កាលានុវត្តភាព និងហានិភ័យនៃការអភិវឌ្ឍបច្ចុប្បន្ន (ដល់ឆ្នាំ២០១៥) ត្រូវបានដោះស្រាយរួមទាំងការសម្របសម្រួលរវាងបណ្តាប្រទេសអាងទន្លេមេគង្គភាគខាងក្រោម និងកិច្ចសហប្រតិបត្តិការជាមួយចិនដែលសម្រេចបាន សំដៅធានាការកើនឡើងនៃលំហូរទឹកនៅរដូវប្រាំងការអនុវត្តកិច្ចព្រមព្រៀង ស្តីអំពីការរក្សាលំហូរ នៃផ្លូវទឹកនៅតាមតំបន់អាងទន្លេមេគង្គភាគខាងក្រោម ដែលបានអនុវត្ត និងហានិភ័យនៃគម្រោងដែលត្រូវគ្រប់គ្រង។
- កសិកម្មតាមរយៈប្រព័ន្ធស្រោចស្រពសម្រាប់សន្តិសុខស្បៀង និងលប់បំបាត់ភាពក្រីក្រត្រូវបានពង្រីក និងពង្រឹងកាន់តែខ្លាំង។
- និរន្តរភាពសង្គមនិងបរិស្ថាននៃការអភិវឌ្ឍវារីអគ្គីសនី ត្រូវបានពង្រីកយ៉ាងទូលំទូលាយ។
- ចំណេះដឹងសំខាន់ត្រូវបានទទួល ដើម្បីដោះស្រាយពីភាពមិនច្បាស់លាស់ និងការកាត់បន្ថយហានិភ័យ នៃកាលានុវត្តន៍ភាពអភិវឌ្ឍន៍ដែលអាចកើតឡើង។ ចំណេះដឹងទាំនោះរួមមានចំណេះ ដឹងអំពីបម្លាស់ទី និងការប្រែប្រួលនូវបរិមាណត្រី កំណក និងលំហូរកករ(ដីល្បាប់) និងជីវជាតិនានាបម្រែបម្រួលជីវចម្រុះ និងផលប៉ះពាល់ជីវភាពរស់នៅនិងសង្គម។
- ជម្រើសសម្រាប់ចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍ និងហានិភ័យដែលបានកំណត់។
- យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- ការពិចារណាលើផែនការអាង ដែលត្រូវបានបញ្ចូលទៅក្នុងការធ្វើផែនការថ្នាក់ជាតិ និងទៅក្នុងប្រព័ន្ធនិយ័តកម្មថ្នាក់ជាតិ។

## យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងអាងទន្លេ

យុទ្ធសាស្ត្រនេះកំណត់អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង។ យុទ្ធសាស្ត្រនេះមានសារៈសំខាន់ដើម្បីធានាឱ្យការអភិវឌ្ឍអាងមាននិរន្តរភាព ដូចខាងក្រោមនេះ :

- គោលបំណង និងយុទ្ធសាស្ត្រគ្រប់គ្រងអាងត្រូវបានកំណត់សម្រាប់វិស័យទាក់ទង់នឹងទឹកក្នុងនោះ មានជលផល ការគ្រប់គ្រងស្បៀង និងគ្រោះរាំងស្ងួត ការគ្រប់គ្រងតំបន់ដីសើម និងនាវាចរណ៍។

- ដំណើរការគ្រប់គ្រងធនធានទឹកនៅកម្រិតជាតិត្រូវបានពង្រឹងរួមទាំងការតាមដានធនធានទឹក ការចេញអាជ្ញាប័ណ្ណប្រើប្រាស់ទឹក និងការគ្រប់គ្រងទិន្នន័យ និងពត៌មាន។

- ដំណើរការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធនៅកម្រិតអាងត្រូវបានពង្រឹងរួមទាំងការអនុវត្តនិតិវិធីរបស់គណៈកម្មការទន្លេមេគង្គទាំងស្ថានភាពនៃការតាមដាន និងការរាយការណ៍អំពីអាង ការតាមដានវដ្តគម្រោង និងរួមទាំងបង្កើនការចូលរួមពីភាគីពាក់ព័ន្ធឱ្យ បានទូលំទូលាយ។

- គោលបំណងផ្នែកសង្គម និងផ្នែកបរិស្ថានច្បាស់លាស់របស់អាង និងសូចនាករមូលដ្ឋានបានត្រូវកំណត់ និង

- កម្មវិធីកសាងសមត្ថភាពគ្រប់គ្រងធនធានទឹកត្រូវបានអនុវត្ត ដោយផ្សារភ្ជាប់ទៅនឹងទស្សនៈផ្តួចផ្តើមរួមរបស់គណៈកម្មការទន្លេមេគង្គ និងបំពេញបន្ថែមសកម្មភាពកសាងសមត្ថភាពថ្នាក់ជាតិ។

## ការអនុវត្តយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ ផ្តល់នូវផែនទីបង្ហាញផ្លូវមួយយ៉ាងច្បាស់លាស់ ដែលកំណត់សកម្មភាពអាទិភាពរយៈពេល និង លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ។ សកម្មភាពដំបូងនៅក្នុងផែនទីបង្ហាញផ្លូវជាការរៀបចំផែនការសកម្មភាពអាង ឆ្នាំ២០១១ ដែលក្នុងនោះមានផែនការសកម្មភាពថ្នាក់តំបន់ និងផែនការចង្អុលបង្ហាញថ្នាក់ជាតិបន្ថែមចំនួន៤ ទៀត ដែលស្របគ្នាទៅនឹងផែនការថ្នាក់ជាតិមួយសម្រាប់ប្រទេសនីមួយៗក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម។ ផែនការចង្អុលនឹងត្រូវផ្សំឡើងដោយសកម្មភាពបន្ថែម ដែលត្រូវបំពេញឱ្យផែនការថ្នាក់ជាតិបច្ចុប្បន្ន សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ។ សកម្មភាពទាំងនេះនឹងខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីអាទិភាព និងតំបន់គោលដៅនៃប្រទេសនីមួយៗ។

ការអនុវត្តយុទ្ធសាស្ត្រនេះ និងការអភិវឌ្ឍផែនការសកម្មភាពអាង គឺជាអាទិភាពស្នូលនៃកម្មវិធី BDP ឆ្នាំ២០១១-២០១៥ ក្រោមផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១១-២០១៥។ ការ

រៀបផែនការចង្អុលបង្ហាញ ថ្នាក់ជាតិ នឹងត្រូវដឹកនាំដោយគណៈកម្មាធិការជាតិទន្លេមេគង្គ (NMCs) ដោយធ្វើការពិគ្រោះយោបល់ជាមួយស្ថានប័នបណ្តាញទទួលខុសត្រូវ និងដោយមានបញ្ចូលទៅក្នុងផែនការតាមវិស័យ និងសេដ្ឋកិច្ចជាតិ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គ (NMCs)។

ការរៀបចំ និងការអនុវត្តផែនការសកម្មភាពថ្នាក់តំបន់ នឹងត្រូវដឹកនាំដោយលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ(NMCs) ។ កម្មវិធីតាមដានការអនុវត្តយុទ្ធសាស្ត្រទូលំទូលាយរួមទាំងលទ្ធផល និងសកម្មភាពនឹងត្រូវបង្កើតឡើងក្នុង ឆ្នាំ២០១១នេះ។

## ស្ថានភាពយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ គឺជាផលិតផលមួយរបស់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គដូចជា កម្ពុជា ឡាវ វៀតណាម និងថៃ ហើយនឹងត្រូវអនុវត្តដោយបណ្តាប្រទេសទាំងនេះដោយមានការគាំទ្រ និងជួយសម្របសម្រួល ពីគណៈកម្មការទន្លេមេគង្គ និងជំនួយ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍សំខាន់ៗ។

ការចូលរួមយ៉ាងសកម្ម និងដោយតម្លាភាពពីអ្នកពាក់ព័ន្ធទាំងអស់នៃទន្លេមេគង្គ គឺជាការចាំបាច់ដើម្បីឱ្យគោលដៅសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងដោយចីរភាព និងដោយសហការល្អលើធនធានទឹកនៅអាងទន្លេមេគង្គភាគខាងក្រោម នឹងសម្រេចទៅបានក្នុងការចែករំលែកផលប្រយោជន៍ដល់ប្រជាជនជាពិសេសអ្នកក្រីក្រ និងអ្នកដែលត្រូវការចាំបាច់។

# តារាងមាតិកា

អក្សរកាត់ xi

១ សេចក្តីផ្តើម ១
១.១ គោលបំណង និងវិសាលភាពនៃយុទ្ធសាស្ត្រ ១
១.២ កម្មវត្ថុ និង ន វិស័យរបស់យុទ្ធសាស្ត្រ ៣
១.៣ អភិក្រមក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រ ៤

២ ផែនការ និងនិន្នាការអភិវឌ្ឍន៍ ១៣
២.១ អាងទន្លេមេគង្គ ១៣
២.២ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកបច្ចុប្បន្ន ១៤
២.៣ និន្នាការអភិវឌ្ឍន៍ និងបញ្ហាប្រឈម ១៥

៣ កាលានុវត្តភាពអភិវឌ្ឍន៍ និងហានិភ័យ ១៩
៣.១ ការវាយតម្លៃជាមូលដ្ឋាន ១៩
៣.២ កាលានុវត្តភាពនិងហានិភ័យនៃការអភិវឌ្ឍធនធានទឹក ២០

៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ២៧
៤.១ ក្របខ័ណ្ឌកាលានុវត្តភាពនៃការអភិវឌ្ឍត្រូវបានកំណត់ ២៧
៤.២ អាទិភាពយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍អាង ២៩
៤.៣ អាទិភាពយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង ៣៥
៤.៤ ការសិក្សា និងគោលការណ៍ណែនាំ ៤០

៥ ការអនុវត្តយុទ្ធសាស្ត្រ ៤៤
៥.១ ផែនទីបង្ហាញផ្លូវ ៤៤
៥.២ តួនាទី និងការទទួលខុសត្រូវ ៤៥
៥.៣ ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើរបាយការណ៍ ៤៦

ឧបសម្ព័ន្ធ: ផែនទីបង្ហាញផ្លូវ ៤៩

# អក្សរកាត់



| | |
|---|---|
| ASEAN | សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BDP | ផែនការអភិវឌ្ឍន៍អាង |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| DOS | ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| GMS | មហាអនុតំបន់មេគង្គ |
| IWRM | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| LMB | តំបន់អាងទន្លេមេគង្គភាគខាងក្រោម |
| LNMC | គណៈកម្មការជាតិទន្លេមេគង្គឡាវ |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MNRE | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន“ថៃ” |
| MONRE | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន“វៀតណាម” |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម “កម្ពុជា” |
| MRC | គណៈកម្មការទន្លេមេគង្គ |
| MRCS | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ |
| MPCC | វេទិកាទន្លេមេគង្គស្តីពីការប្រែប្រួលអាកាសធាតុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NMC | គណៈកម្មាធិការ ជាតិទន្លេមេគង្គ |
| NMCS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គ |
| NPV | តម្លៃសុទ្ធបច្ចុប្បន្ន |
| PDIES | នីតិវិធីសម្រាប់ការដោះដូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន |
| PNPCA | នីតិវិធីសម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុននិងកិច្ចព្រមព្រៀង |
| PMFM | នីតិវិធីសម្រាប់ការរក្សាលំហូរនៅលើទន្លេមេគង្គ |
| PWQ | នីតិវិធីសម្រាប់គុណភាពទឹក |
| PMUM | នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក |
| RBC | គណៈកម្មាធិការអាងទន្លេ |
| RBO | អង្គការរៀបចំអាងទន្លេ |
| SIA | ការវាយតម្លៃហេតុប៉ះពាល់សង្គម |
| TbEIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតំបន់ឆ្លងដែន |
| TNMC | គណៈកម្មការជាតិទន្លេមេគង្គថៃ |
| US$ | ដុល្លារសហរដ្ឋអាមេរិក |
| VNMC | គណៈកម្មការជាតិទន្លេមេគង្គវៀតណាម |
| WREA | រដ្ឋបាលធនធានទឹក និងបរិស្ថាន “ឡាវ” |

# ១. សេចក្តីផ្តើម

## ១.១ គោលបំណង និងវិសាលភាពនៃយុទ្ធសាស្ត្រ

**គោលបំណង:** យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងផ្អែកតាមគោលការណ៍ គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) គឺជាសេចក្តីថ្លែងការណ៍របស់បណ្តាប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោម(កម្ពុជា ឡាវ ថៃ និងវៀតណាម) ដែលបានកំណត់ថា តើនឹងត្រូវចែករំលែកត្រូវប្រើប្រាស់ គ្រប់គ្រង់ និងត្រូវអភិរក្សទឹក និងធនធានពាក់ព័ន្ធនៃទន្លេមេគង្គយ៉ាងដូចម្តេច? ដើម្បីសម្រេចបានគោលដៅនៃកិច្ចព្រមព្រៀងលើកិច្ចសហប្រតិបត្តិការសម្រាប់ធ្វើ ការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គ ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៥ (កិច្ចព្រមព្រៀងមេគង្គ១៩៩៥) ។

យុទ្ធសាស្ត្រនេះ គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់គណៈកម្មការ ទន្លេមេគង្គចំពោះកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងពិសេសគឺជាការឆ្លើយតបមួយទៅនឹងមាត្រាទី២ ដែលស្នើឱ្យមានការបង្កើតនូវផែនការអភិវឌ្ឍន៍អាង។ យុទ្ធសាស្ត្រនេះផ្តល់ការណែនាំដោយឡែក សម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងអាងដោយចីរភាពផ្តោតលើការត្រួតពិនិត្យ និងការធ្វើបច្ចុប្បន្នភាពដោយគណៈកម្មាការ ទន្លេមេគង្គរៀងរាល់៥ឆ្នាំម្តង។

**ក្រមខ័ណ្ឌយុទ្ធសាស្ត្រ:** យុទ្ធសាស្ត្រនេះផ្តល់ជាវិភាគទាន នូវដំណើរការធ្វើផែនការបន្សុំដ៏ទូលំទូលាយមួយ ដែលផ្សារភ្ជាប់ការធ្វើផែនការនៅថ្នាក់ជាតិនិងថ្នាក់តំបន់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅអាងទន្លេមេគង្គភាគខាងក្រោម។ វាត្រូវបានចាត់ទុកជាសេណារីយ៉ូអភិវឌ្ឍន៍ដោយព្យាករណ៍មួយក្នុងរយៈពេល៥០ឆ្នាំ ដើម្បីបង្កើតឡើងនូវទស្សនវិស័យ ការគ្រប់គ្រង និងអភិវឌ្ឍន៍អាង រយៈពេល២០ឆ្នាំ។ វាផ្តល់នូវទស្សនវិស័យចម្រុះមួយអំពីអាងសំរាប់យកទៅពិចារណាផ្ទៀងផ្ទាត់ ជាមួយផែនការអភិវឌ្ឍន៍ ធនធានទឹក

គោលណាការណ៍គ្រប់គ្រងទឹកចម្រុះ (IWRM) គឺជាដំណើរការមួយជួយលើកស្ទួយដល់ការគ្រប់គ្រងការអភិវឌ្ឍទឹកដី និងធនធានពាក់ព័ន្ធនានាដោយការសម្របសម្រួលក្នុងន័យបង្កើតនូវសុខុមាលភាព សេដ្ឋកិច្ច និង សង្គម ឱ្យបានអតិបរមាទៅតាមដំណើរមួយ ដែលមានតុល្យភាពដោយមិនចាំបាច់មានការសម្រុះសម្រួល ដើម្បីនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីឡើយ។

គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) មិនមែនជាចំណុចបញ្ចប់ដោយខ្លួនឯងនោះ ប៉ុន្តែជាមធ្យោបាយមួយនៃការសម្រេច បានកម្មវត្ថុយុទ្ធសាស្ត្រចំបងៗទាំងបី គឺភាពសក្តិសិទ្ធី (ប៉ុនប៉ងក្នុងន័យបង្កើន សុខុមាលភាព សេដ្ឋកិច្ច និងសង្គមឱ្យបានជាអតិបរមាដែលមិន គ្រាន់តែបានពីធនធានទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីការវិនិយោគទៅលើការផ្តល់សេវាកម្មទឹកទៀតផង) ។ សមធម៌ (ទៅលើការបែងចែកធនធានកម្រ និងសេវាកម្មនៅទូទាំងបណ្តុំ សង្គម និង សេដ្ឋកិច្ច) និងនិរន្តរភាព (ស្របពេលដែលមូលដ្ឋានធនធានទឹក និងប្រព័ន្ធអេកូឡេស៊ីពាក់ព័ន្ធនានាមានកំណត់)។

នៅថ្នាក់ជាតិពេលបច្ចុប្បន្ន និងអនាគត ដើម្បីធានាតុល្យភាពមួយ ដែលអាចទទួលយកបានរវាងផលប្រយោជន៍សេដ្ឋកិច្ច បរិស្ថាន និងសង្គម និងផលប្រយោជន៍រួម រវាងប្រទេស នៅក្នុងតំបន់អាងមេគង្គភាគខាងក្រោមដូចដែលយុទ្ធសាស្ត្រនេះ

- កំណត់វិសាលភាពនៃកាលានុវត្តភាពសំរាប់ការអភិវឌ្ឍធនធានទឹក (វារីអគ្គីសនី ការស្រោចស្រព ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត) ហានិភ័យនៃការអភិវឌ្ឍ និងសកម្មភាពចាំបាច់ ដែលត្រូវធ្វើ ដើម្បីបង្កើនកាលានុវត្តភាព និងកាត់បន្ថយហានិភ័យ។

- កំណត់កាលានុវត្តភាពដទៃទៀតដែលពាក់ព័ន្ធទឹកដូចជា (ការគ្រប់គ្រងជលផល នាវាចរណ៍ បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី ការគ្រប់គ្រងទីជម្រាល) និង

- ផ្តល់ដំណើរការដោយមានការសម្របសម្រួលដែលការចូលរួម និងមានតម្លាភាពដើម្បីលើកស្ទួយដល់ការអភិវឌ្ឍដោយចីរភាព។

**តម្រូវការសម្រាប់យុទ្ធសាស្ត្រ:** យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលមានការផ្លាស់ប្តូរធំៗ នៅពេលដែលការអភិវឌ្ឍទន្លេមេគង្គទ្រង់ទ្រាយធំ និងរហ័សបានកើតឡើងទៅហើយ វីងទំនប់វារីអគ្គីសនីនៅទន្លេឡានឆាងនៃប្រទេសចិនត្រូវបានសាងសង់ (ឡានឆាងអាងទន្លេមេគង្គខ្សែទឹកខាងលើ) និងនៅតាមទន្លេមេនៃទន្លេមេគង្គភាគខាងក្រោមកំពុងធ្វើឱ្យមានការប្រែប្រួលដល់របបលំហូរទឹកទន្លេមេគង្គ។ ការកើនឡើងតំរូវការរបស់ប្រទេសសមាជិក អ្នកវិនិយោគ និងអ្នកពាក់ព័ន្ធសំរាប់ការផ្តល់នូវទស្សនវិស័យចម្រុះស្តីពីអាងលើផែនការអភិវឌ្ឍន៍ធនធានទឹកថ្នាក់ជាតិ និងផលប៉ះពាល់បន្តបន្ទាប់របស់វាកាន់តែកើនឡើង។ តម្រូវការនេះកាន់តែជាក់ស្តែងសំរាប់បរិបទនៃការធ្វើផែនការណ៍ ដែលក្នុងនោះប្រតិបត្តិការរបស់វិស័យឯកជន គឺជាចលករសំខាន់ក្នុងការធ្វើឱ្យមានការផ្លាសប្តូរ។

> យុទ្ធសាស្ត្រនេះ ជាក្របខ័ណ្ឌសកម្មមួយដែលនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ ដើម្បីធានាថាការធ្វើសេចក្តីសម្រេចអំពីទឹក និងអំពីធនធានពាក់ព័ន្ធនា នាពីអាស្រ័យនឹងការធ្វើបច្ចុប្បន្នកម្មចំណេះដឹងអំពីអាង។

យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងក្នុងខណៈពេលដែលយើងមិនទាន់មានទិន្នន័យ និងចំណេះដឹងគ្រប់គ្រាន់។ ប៉ុន្តែសម្ពាធនៃការអភិវឌ្ឍយ៉ាងគំហុក ក៏ទាមទារនូវសកម្មភាពអនុវត្តយុទ្ធសាស្ត្រដែរ។ យុទ្ធសាស្ត្រនេះជាក្របខ័ណ្ឌសកម្មមួយដែលនឹងត្រូវពិនិត្យឡើង និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ ដើម្បីធានាថាការធ្វើសេចក្តីសម្រេចអំពីទឹក និងអំពីធនធានពាក់ព័ន្ធនឹងត្រូវបានធ្វើឡើងដោយផ្អែកលើចំណេះដឹងថ្មីៗអំពីអាង។ បច្ចុប្បន្នកម្មបន្ទាប់មកទៀតត្រូវបានរំពឹងថានឹងធ្វើក្នុងឆ្នាំ ២០១៥។

**ព្រឹត្តិការណ៍សំខាន់ៗ:** យុទ្ធសាស្ត្រនេះ បង្ហាញពីព្រឹត្តិការណ៍សំខាន់ក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការមេគង្គ។ ព្រឹត្តិការណ៍ទាំងនេះត្រូវបានគ្រប់គ្រង និងដឹកនាំដោយបណ្តាប្រទេសនៅតាមអាងទន្លេមេគង្គភាគខាងក្រោមតាមរយៈដំណើរការមួយនៃការវិភាគផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងផលប៉ះពាល់ដែលអាចកើតមាននិងត្រូវបានជូនដំណឹងដោយមានការជម្រុញពីអ្នកពាក់ព័ន្ធនៅក្នុងអាងនេះ។

> យុទ្ធសាស្ត្រនេះបង្ហាញពីគោលវាស់វែងសំខាន់មួយក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការមេគង្គ។